**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៨ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## សម្រេច

**ប្រការ១ :** តែងតាំងគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** | | ប្រធានកិត្តិយស |
| ២. | លោកជំទាវវេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ប្រធាន |
| ៣. | លោកជំទាវ **ឃឹម ចំរើន** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. | លោកជំទាវ **ម៉ិញ ភុសនី** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥. | លោកជំទាវ **ច័ន្ទ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៦. | លោកជំទាវ **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៧.លោកជំទាវ | **ស៊ើុង សរសុចិន្តា** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ៨.លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិកា |
| ៩.លោកជំទាវ | **ទូច សារ៉ុម** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិកា |
| ១០.លោកជំទាវ | **មាសសាឯម ដានី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកា |
| ១១.លោកជំទាវ | **ម៉ាលី សុជាតា** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិកា |
| ១២.លោកជំទាវ | **កែវ ចរិយា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកា |
| ១៣.លោកជំទាវ | **ជ្រឹង បុទុមរង្សី** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិកា |
| ១៤.លោកជំទាវ | **ច័ន្ទ ហារ៉ានវឌ្ឍី** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ១៥.លោកជំទាវ | **ទន់ សារ៉ីម** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៦.លោកជំទាវ | **ឈូក ឈូវឌ្យ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិកា |
| ១៧.លោកជំទាវ | **ហ៊ូ និរមិត្តា** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ១៨.លោកជំទាវឧត្តមសេនីយ៍ឯក | **យក់ សុខា** | អគ្គស្នងការរងនគរបាលជាតិ | សមាជិកា |
| ២៩.ឧត្តមសេនីយ៍ទោ | **ហ៊ាង ឆវី** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិកា |
| ២០.លោកជំទាវ | **កែវ សុខពិសី** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិកា។ |

**ប្រការ២ :** អនុប្រធាន និងសមាជិកានៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៣ :** សេចក្តីសម្រេចលេខ៣៥ សសរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៤ កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ